# សម្ភាសន៍ជាមួយឈ្មោះ រី ផល ភេទស្រី អាយុ៥២ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ “យោធា”

## ស្រុកកំណើតនៅភូមិត្រពាំងក្រហម ឃុំត្រពាំងក្រហម ស្រុកលុំផាត់ ខេត្តរតនគិរី

## រស់នៅភូមិទួលចារ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

## ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣

## សម្ភាសន៍ដោយៈ សោម ប៊ុនថន

## ០០:៤៩:៥១

## ២៦ទំព័រ

ប៊ុនថនៈ ចឹងដំបូងកុំឲ្យខាតពេលខ្ញុំសុំអនុញ្ញាតសម្ភាសអ្នកមីង?

ផលៈ ចាស ។

ប៊ុនថនៈ ដោយសារខ្ញុំកត់ចូលសៀវភៅមិនទាន់ ខ្ញុំសុំថតសម្លេងអ្នកមីង?

ផលៈ ចាស ។

ប៊ុនថនៈ ចឹងមីងអនុញ្ញាតឲ្យសម្ភាសហើយមីង?

ផលៈ ចាស ។

ប៊ុនថនៈ មីងឈ្មោះអីដែរ?

ផលៈ ខ្ញុំឈ្មោះ រី ផល ។

ប៊ុនថនៈ មីងអាយុប៉ុន្មាន?

ផលៈ អាយុ៥២ឆ្នាំ ។

ប៊ុនថនៈ មីងមានស្រុកកំណើតនៅភូមិឃុំអីដែរ?

ផលៈ ខ្ញុំនៅរតនគិរីនោះ ។

ប៊ុនថនៈ ភូមិអីមីង?

ផលៈ ភូមិត្រពាំងក្រហម ។

ប៊ុនថនៈ ឃុំអី?

ផលៈ មិនដឹងជាឃុំអីទេ ខ្ញុំចេញពីស្រុកមកយូរហើយ ចាំតែស្រុកលុំផាត់ ខេត្តរតនគិរី ។

ប៊ុនថនៈ មីងមិនមែនជនជាតិទេ?

ផលៈ ខ្មែរ ។

ប៊ុនថនៈ បច្ចុប្បន្នមីងនៅភូមិឃុំអីដែរ?

ផលៈ ខ្ញុំនៅភូមិទួលចារ ។

ប៊ុនថន៖ ឃុំទំនប់ដាច់មីង?

ផល៖ ចាស ។

ប៊ុនថន៖ មីងមានបងប្អូនប៉ុន្មាននាក់?

ផល៖ ខ្ញុំមានបងប្អូនពីរនាក់ បងប្អូនទើបជួបគ្នាបានពីរឆ្នាំហ្នឹង ។

ប៊ុនថន៖ តាំងពីមីងចេញពីស្រុក?

ផល៖ ចាស! តាំងពីឆ្នាំ១៩៧៦ ទើបជួបគ្នាឆ្នាំ២០១២ ។

ប៊ុនថន៖ យ៉ាងម៉េចបានជួបគ្នា?

ផល៖ ប៉ុស្តិ៍បាយ័នរកឲ្យ ។

ប៊ុនថន៖ គេមានហៅមីងទៅភ្នំពេញជួបទេ?

ផល៖ ចាស! ហៅទៅជួប គេមករកឲ្យទៅជួបគ្នានៅភ្នំពេញហ្នឹង ទើបជួបគ្នាបានពីរឆ្នាំ ។

ប៊ុនថន៖ ចឹងឥឡូវគាត់នៅខាងខេត្តរតនគិរី?

ផល៖ គាត់នៅខាងខេត្តព្រះវិហារ ។

ប៊ុនថន៖ ប្អូនមីង?

ផល៖ បង ។

ប៊ុនថន៖ ឈ្មោះអីវិញ?

ផល៖ ឈ្មោះ ចាន់ ណាង ។

ប៊ុនថន៖ ត្រកូលខុសគ្នា?

ផល៖ ត្រកូលខុសគ្នា ព្រោះបែកពីគាត់តូចពេកខ្ញុំចេះតែដាក់ទៅត្រកូលណាណីទេ ដល់ហើយប្រកាន់ត្រកូលហ្នឹងតែម្តងទៅ ។

ប៊ុនថន៖ គាត់នៅខាងព្រះវិហារ?

ផល៖ ចាស ។

ប៊ុនថន៖ គាត់នៅស្រុកអីវិញ?

ផល៖ ស្រុកត្បែង ។

ប៊ុនថន៖ នៅទីរួមខេត្តតែម្តង?

ផល៖ អត់ទេ គាត់នៅដាច់ស្រយាល គាត់អ្នកអត់នៅឆ្ងាយពីគេ ។

ប៊ុនថន៖ គាត់ធ្វើអីដែលសព្វថ្ងៃហ្នឹង?

ផល៖ គាត់អត់មានការងារអីធ្វើដែរ ធ្វើស្រែលិចទឹក អត់មានស្អីផង ប្រកបរបររកត្រីអីបន្តិចបន្តួចចឹងទៅ ។

ប៊ុនថន: ចឹងឪពុកម្ដាយមានដឹងដំណឹងទេ?

ផល: ឪពុកម្ដាយស្លាប់អស់ ។

ប៊ុនថន: ស្លាប់ជំនាន់ណាដែរ?

ផល: ស្លាប់៧៩ ម្ដាយស្លាប់ឆ្នាំ៨៥ ។

ប៊ុនថន: ឪពុកមីងឈ្មោះអីវិញ?

ផល: ឪពុកខ្ញុំឈ្មោះ រី ។

ប៊ុនថន: រី អីវិញ?

ផល: អត់ស្គាល់ ។

ប៊ុនថន: ម្ដាយ?

ផល: ម្ដាយឈ្មោះ ម៉ៅ ។

ប៊ុនថន: ចឹងឪពុកស្លាប់៧៩ពេលហ្នឹងមីងដឹងដែរ?

ផល: អត់មានដឹងថា គាត់ស្លាប់ពេលណាទេ តែគ្រាន់ថាស្លាប់ឆ្នាំហ្នឹង ព្រោះកាលហ្នឹងវត់យួន កាល៧៩វត់យួនមកបានប៉ុន្មានខែខ្ញុំបែកពីគាត់ទៅ គាត់ស្លាប់ទៅមិនដឹងគាត់យ៉ាងណាយ៉ាងណីខ្ញុំអត់ដែរ ។

ប៊ុនថន: មីងពីតូចបានរៀនដល់ថ្នាក់ណាដែរ?

ផល: ខ្ញុំរៀនបានត្រឹមថ្នាក់ទី២ ។

ប៊ុនថន: ទី២សង្គមចាស់?

ផល: ទី២សម័យបីឆ្នាំ សម័យបីឆ្នាំហឹងដឹងថាយ៉ាងម៉េចទេ ។

ប៊ុនថន: រៀននៅណាវិញ?

ផល: ខ្ញុំរៀននៅរតនគិរី រៀនអត់មានសាលាអីទេ ខ្ញុំរៀនក្នុងព្រៃ រៀនតាមព្រៃម្ងប់ឈើម្ងប់អីហ្នឹង អត់មានបានរៀនសាលាទេ ។

ប៊ុនថន: ពីណាអ្នកបង្រៀនកាលហ្នឹងគ្រូគេ?

ផល: គ្រូគេ ។

ប៊ុនថន: គ្រូខាងបដិវត្តហ្នឹង?

ផល: ចាស!គ្រូបដិវត្តគេហ្នឹងបង្រៀន ។

ប៊ុនថន: មីងឪពុកម្ដាយមីងធ្វើអីវិញ?

ផល: គាត់ធ្វើស្រែដល់ពេលខ្ញុំធំដឹងមកចូលសម័យរួមហ្នឹង ចូលសង្គមរួមហ្នឹង ។

ប៊ុនថន: ចូលឆ្នាំណាដែលមីង?

ផលៈ ចូលពេលបាយរួមហ្នឹង៧០ ប៉ុន្មានខ្ញុំតូចដេលមិនច្បាស់ ៧៦-៧៧ហ្នឹង ៧៦មិនដឹង៧៧មិនដឹងខ្ញុំមិនច្បាស់ដែរ ហូបបាយរួមហ្នឹង ។

ប៊ុនថនៈ ចឹងពេលមានរដ្ឋប្រហារអីមីងមានដឹងទេ រដ្ឋប្រហារលន់ នល់ ទម្លាក់សម្តេច?

ផលៈ ខ្ញុំអត់ដឹងទេ ។

ប៊ុនថនៈ ចឹងពេលឆ្នាំ៧៥ទទួលជ័យជន្នះ មីងនៅណាដែរ?

ផលៈ ចាស! នៅរតនគិរី ។

ប៊ុនថនៈ កាលហ្នឹងមីងចូលកងហើយនៅ ឈ្នះ៧៥ហ្នឹង?

ផលៈ នៅទេ ដល់៧៧បានចូលកងកុមារ ។

ប៊ុនថនៈ ចឹង៧៧ហើយ?

ផលៈ ចាស ។

ប៊ុនថនៈ បន្ទាប់ពីឈ្នះហើយបានមីងចូលកង?

ផលៈ ចាស! ៧៧ចូលកងកុមារ ។

ប៊ុនថនៈ ចឹងចូលកងកុមារនៅក្នុងភូមិឬមួយនៅណា?

ផលៈ ចាស! នៅក្នុងភូមិខ្លះ ចេញក្រៅភូមិខ្លះចឹងទៅ ។

ប៊ុនថនៈ ក្នុងភូមិត្រពាំងក្រហមហ្នឹង?

ផលៈ ចាស ។

ប៊ុនថនៈ ចឹងត្រពាំងក្រហមហ្នឹង បច្ចុប្បន្នស្រុកកូនមុំមីង?

ផលៈ ហ្នឹងហើយស្រុកកូនមុំ ។

ប៊ុនថនៈ ភូមិត្រពាំងក្រហម ឃុំត្រពាំងក្រហម?

ផលៈ ចាស ។

ប៊ុនថនៈ ព្រោះឆ្នាំទៅមួយនោះខ្ញុំបានទៅដែរ ស្រុកកូនមុំហ្នឹង ភូមិត្រពាំងក្រហមទៅវត្តត្រពាំងក្រហមហ្នឹង?

ផលៈ ចាស! ផ្ទះខ្ញុំនៅម្តុំជិតភ្នំ នៅតាមដងផ្លូវហ្នឹងមិនមានភ្នំតាមផ្លូវ ផ្ទះខ្ញុំនៅខាងលិចភ្នំហ្នឹង ផ្ទះហ្នឹងមិនមែនផ្ទះអីនេះទេ យូរណាស់ហើយ ។

ប៊ុនថនៈ កាលពីមុនស្រុកលុងផាត់មីង?

ផលៈ ចាស! ស្រុកលុងផាត់ចេះតែដាក់ទៅកាលខ្ញុំចូលកុមារហ្នឹងទេ ខ្ញុំមិនដឹងដែលទេ ។

ប៊ុនថនៈ តែបច្ចុប្បន្នភូមិត្រពាំងក្រហម?

ផលៈ ចាស ។

ប៊ុនថន: ចឹងមីងចូលក្នុងកងកុមារហ្នឹង មីងនៅក្នុងភូមិដដែលឬមួយនៅភូមិផ្សេង?

ផល: ខ្លះនៅក្នុងភូមិចឹងទៅ ខ្លះនៅភូមិផ្សេងទៅ ស្រេចតែគេត្រូវការដឹកប្រឡាយដឹកអណ្ដូងឬដឹកអីណាចឹងយើងទៅភូមិផ្សេងទៅ ។

ប៊ុនថន: ចូលច្រើនគ្នាទេ មីងកងកុមារហ្នឹង?

ផល: ចូលទាំងអស់ ចាប់ពីអាយុ៩ឆ្នាំ១០អីហ្នឹងចូលកងកុមារហើយ មានកុមារនៅផ្ទះ កុមារចេញពលកម្មក្រៅចឹងទៅ ។

ប៊ុនថន: នៅផ្ទះ?

ផល: នៅផ្ទះហ្នឹង គ្រាន់យើងនៅកន្លែងរួម កាលនៅក្នុងភូមិ ។

ប៊ុនថន: បាទ!ចឹងប្រធានកងកុមារជាពីណាវិញ?

ផល: ខ្ញុំភ្លេចអស់ហើយប្រធានកងកុមារមិនដឹងជាពីរណាពីណាទេ មានតែគ្រូហ្នឹងតែភ្លេចឈ្មោះគ្រូអស់ហើយ យូរពេក ។

ប៊ុនថន: គ្រូបង្រៀនហ្នឹង?

ផល: ចាស ។

ប៊ុនថន: ចឹងក្រៅពីការងារដឹកប្រឡាយអីហ្នឹងមានធ្វើអីទៀតមីង?

ផល: ខ្លះស្ទូងដញ្ជូនកណ្ដាប់ចឹងទៅ ខ្លះប្រូតជួយរើសកណ្ដាប់ដាក់រទេះទៅ ឲ្យតែអង្គការចាត់ចែង ។

ប៊ុនថន: ពិបាកដែលការងារ?

ផល: ការងារពិបាកដែលហ្នឹង ។

ប៊ុនថន: ពិបាកយ៉ាងម៉េចមីង?

ផល: បើយកត្រូវការងារកសិករមិនពិបាកអីទេ ដឹកប្រឡាយអីគ្រាន់ពិបាកយើងអត់មានសម្រាកឲ្យបានត្រឹមត្រូវ វាអត់មានបានសម្រាកពេលយប់យើងឥឡូវយប់ឡើងយើងសម្រាក មុនពេលយប់ឡើងទៅធ្វើការមួយម៉ោងទៅពីរម៉ោងទៀត ក្រោយពីធ្វើការមកយើងរៀនខ្លះទៀតរៀនអក្សរហ្នឹង ខ្ញុំពីប្រលប់ចឹងម៉ោង៦អីទៅដឹកប្រឡាយសែងដីចឹងទៅ ។

ប៊ុនថន: បាទ ។

ផល: ហើយដល់ម៉ោង៩ម៉ោង១០មករៀនមួយម៉ោងពីរម៉ោងបានសម្រាកយប់ ។

ប៊ុនថន: ៩ទៅ១០យប់ហ្នឹង?

ផល: ចាស!ហើយថ្ងៃក៏ចឹងដែលព្រលឹមឡើងយើងទៅពលកម្មតាមធម្មតា ខ្លះប្រូតៗខ្លះស្ទូងៗចឹងទៅដល់ពេលម៉ោង១១ហូបបាយហើយរៀន រៀនមួយម៉ោងពីរម៉ោងចឹងដល់ម៉ោង១ចុះទៅវិញ ចឹងបានខ្ញុំរៀនបានប៉ុណ្ណឹង រៀនអត់មានសាលាអីត្រឹមត្រឹមទេ ខ្ញុំនោះ ។

ប៊ុនថន: រៀនម៉ោង៩ ម៉ោង១០ ពេលថ្ងៃ?

ផល: ចាស! ពេលថ្ងៃម៉ោង១១ យើងឡើងមកហូបបាយ ម៉ោង១១កន្លះចូលរៀនម៉ោង១ចុះទៅពលកម្មវិញ ទាំងយប់ទាំងថ្ងៃចឹងឯង តែគ្រាន់យប់រៀនម៉ោង១១ឈប់ ។

ប៊ុនថន: រៀនហ្នឹងរៀនពីអីវិញ?

ផល: រៀនអក្សរខ្មែរយើងហ្នឹង ។

ប៊ុនថន: រៀនអក្សរហើយមានរៀនអីទៀត?

ផល: រៀនអក្សរនិងលេខហ្នឹង ។

ប៊ុនថន: ចឹងមីងមកនៅជាមួយឪពុកម្ដាយវិញទេ ពេលចូលកងកុមារនៅជាមួយឪពុកម្ដាយឬក៏បំបែកចេញហើយ?

ផល: អត់ទេ ពេលថ្ងៃណាយើងសុំច្បាប់បានមកលេងចឹងបានមកលេងជាមួយឪពុកម្ដាយបានមួយយប់ពីរយប់អីចឹងទៅ ក្រៅពីហ្នឹងនៅកន្លែងកងកុមារហ្នឹង គេធ្វើផ្ទះវែងចឹងទៅកងកុមារហ្នឹងដេករួមគ្នាចឹងទៅ ។

ប៊ុនថន: ចឹងមានជនជាតិអីចូលជាមួយគ្នាទេ?

ផល: អត់មានទេ សុទ្ធតែខ្មែរ ។

ប៊ុនថន: ជនជាតិភាគតិចអី ខ្មែរទាំងអស់?

ផល: ចាស ។

ប៊ុនថន: មីងនៅកងកុមារយូរទេ?

ផល: ខ្ញុំនៅឆ្នាំ៧៧ដល់៧៩ ។

ប៊ុនថន: ៧៩មីងទៅណាវិញ?

ផល: ៧៩ហ្នឹងរត់ចេញពីកងកុមារហ្នឹង ចូលព្រៃតាមហ្នឹងមក ។

ប៊ុនថន: ចូលទៅតាមពីណាវិញ?

ផល: ៧៩តាមម៉ែ ។

ប៊ុនថន: រត់ទៅណាវិញមីង?

ផល: និយាយរឿងរត់ចឹង ខ្ញុំមិនដឹងឆ្លើយម៉េចទៅ ។

ប៊ុនថន: រត់ទៅខាងណាវិញ?

ផល: ខ្ញុំរត់ពីហ្នឹងមកទៅមណ្ឌលគិរី ទៅពីមណ្ឌលគិរីទៅដឹងថាទៅខាងណាខាងណីទៀតនៅក្នុងព្រៃហ្នឹងប៉ុន្មានឆ្នាំ តាំងពី៧៩ដល់៨០ បានមកនៅលើភ្នំនេះ ។

ប៊ុនថន: ចឹងមួយឆ្នាំមីង?

ផលៈ ចាស ។

ប៊ុនថនៈ ចឹងរត់ទៅហ្នឹងមានប្រជាជនទៅជាមួយច្រើនទេ មីង?

ផលៈ ប្រជាជនច្រើនគ្រួសារដែរ ជាមួយទាហានជាមួយទ័ពអីគេចឹង ។

ប៊ុនថនៈ ចឹងនៅលាយឡំគ្នាទៅ?

ផលៈ ចាស! នៅលាយឡំគ្នាមានទ័ពមានប្រជាជនចឹងទៅ តែប្រជាជនពីរបីគ្រួសារទេ ។

ប៊ុនថនៈ ចឹងទៅជាមួយម្ដាយហ្នឹងជាប្រជាជនទេ?

ផលៈ ចាស ។

ប៊ុនថនៈ ចុះឪពុកមីង?

ផលៈ ឪពុក៧៩ហ្នឹងរត់ដែរ រត់បាន៥ខែឪពុកខ្ញុំបានគាត់បែក ។

ប៊ុនថនៈ គាត់បែកចេញ?

ផលៈ ចាស! គាត់បែកចេញទៅ បែកចេញបានប្រហែលជាបីខែបានឮដំណឹងថាគាត់ស្លាប់ ព្រោះបែកគ្នាហ្នឹង បែកមានសង្គ្រាមចឹង ហើយដល់ពេលសង្គ្រាមកើតឡើងមកបែកគ្នាទៅ ខ្ញុំបានពីរអ្នកម៉ែឪពុកបែកតែឯងទៅ ។

ប៊ុនថនៈ ចុះបងស្រី?

ផលៈ បងស្រីហ្នឹងដូចខ្ញុំប្រាប់គាត់តាំងពីខាងដើមចឹង បងស្រីខ្ញុំបាត់ចេញពីផ្ទះតាំងពីឆ្នាំ៧៦ មិនដឹងជាគាត់ទៅធ្វើការខាងណាទេ ខ្ញុំមិនដឹងទេ ដឹងថាអង្គការយកទៅ រហូតមកទើបជួបគ្នាពីរឆ្នាំហ្នឹង បានដឹងសាច់រឿង ។

ប៊ុនថនៈ ចូលក្នុងព្រៃពី៧៩ដល់៨០ ហ្នឹង ការរស់នៅក្នុងព្រៃយ៉ាងម៉េចដែលមីង?

ផលៈ រស់នៅក្នុងព្រៃចឹងទៅ ដើរខែប្រាំងចឹងយប់ណាដេកហ្នឹងទៅ ។

ប៊ុនថនៈ អត់មានសង់ជាខ្ទមអីទេ?

ផលៈ អត់ទេ ជួនណាមានដើមឈើធំចឹងនាំក្រាលកន្ទេលក្រាលភួយអីចឹងជុំវិញដើមឈើហ្នឹងទៅ ភ្លឺឡើងទៅទៀតទៅមិនដឹងជាទៅខាងណា ខាងណាដែលខ្ញុំចេះតែដើរជាមួយគេទៅដើរថ្ងៃយប់សម្រាកទៅ ។

ប៊ុនថនៈ ចឹងការហូបចុកអី?

ផលៈ កាលហូបចុកពី៧៩មកទល់៨០ ហូបក្ដួចនិងដំឡូង ។

ប៊ុនថនៈ ចឹងអំបិល ស្ករទឹកត្រីអីនោះ?

ផលៈ អត់មានទេ ទឹកត្រីស្ករបីចេង មិនដែលហូបផង ។

ប៊ុនថនៈ ចឹងអត់មានអំបិលហូបយ៉ាងម៉េចទៅ?

ផលៈ	អំពិលមានពូៗ នៅរកក្នុងភូមិចឹងទៅមានក៏ដូរចឹងទៅណាស់	មាសមួយខ្សែចឹងដូរអំបិលបាន មួយគីឡូពីរគីឡូហួបទៅ ។

ប៊ុនថនៈ	បែកគ្នាហួបទៅ?

ផលៈ	ចាស ។

ប៊ុនថនៈ	ចុះឈើស្អាត់អីនៅក្នុងព្រៃយ៉ាងម៉េចទៅ?

ផលៈ	ឈើស្អាត់ចេះតែកាប់ដើមឈើហួបទៅ គ្រូនចាញ់គេហួបដើមស្ដៅ កាប់ដើមស្ដៅដាំហួបពេល យើងក្ដៅខ្លួនបេះស្លឹកឈើដាំហួបចឹងទៅ ។

ប៊ុនថនៈ	ចឹងបាត់ដែរ?

ផលៈ	ចាស! បាត់ដែរ ។

ប៊ុនថនៈ	ចឹងបើឈឺធ្ងន់អីធ្វើយ៉ាងម៉េចទៅ?

ផលៈ	បើឈឺធ្ងន់ស្លាប់ទៅនៅក្នុងព្រៃមិនដឹងធ្វើយ៉ាងម៉េច តែអត់មានស្លាប់ចឹងផង ស្លាប់និងគេបាញ់ ស្លាប់តែបើជំងឺអត់មានទេ ។

ប៊ុនថនៈ	ចឹងនៅក្នុងហ្នឹងមានអ្នកដឹកនាំអី ដូចថាក្នុងព្រៃមានអ្នកមានអ្នកដឹកនាំ?

ផលៈ	នៅក្នុងព្រៃទ័ពគេ កងទ័ពគេហ្នឹងដឹកនាំចឹងទៅនាំដើរចឹងទៅពីមួយថ្ងៃទៅមួយថ្ងៃ ។

ប៊ុនថនៈ	ចឹងមីងអត់មានបានចូលក្នុងកងទេ?

ផលៈ	ចាស!អត់ទេ យើងគ្រាន់តែតាមគេចឹងទៅ យើងចេះតែទៅតាមគេចឹងទៅ គេហួបគេយើង ហួបយើងចឹងទៅ ។

ប៊ុនថនៈ	ចឹងមានតែបីគ្រួសារទេ ដែលមីងនិយាយថាទៅចូលក្នុងព្រៃ?

ផលៈ	ចាស!តែក្រោយមកទៀត គ្រួសារគេហ្នឹងចេះតែបែកគ្នាទៅមិនដឹងជាទៅណាអស់ទៅខ្ញុំនៅតែ ពីរនាក់ម៉ែទេ ជាមួយទ័ពនោះមកទល់គ្នាឆ្នាំ៨០ ហ្នឹងបានឡើងដល់លើភ្នំ ។

ប៊ុនថនៈ	ទ័ពហ្នឹងមីងមានដឹងថាទ័ពខាងណាទេ?

ផលៈ	ទ័ពគេខាង៨០ ១ ហ្នឹង ដឹងថាខាងណាទេ ។

ប៊ុនថនៈ	គាសារឿន ហ្នឹង?

ផលៈ	ចាស!កងពល៨០ ១ ហ្នឹង ។

ប៊ុនថនៈ	គាសារឿន ០៥ ហ្នឹង?

ផលៈ	ចាស ។

ប៊ុនថនៈ	ចឹងមីងនៅជាប់កងពលហ្នឹងតាំងពីឆ្នាំ៧៩?

ផលៈ	ចាស ។

ប៊ុនថន៖ អ្នកណាដឹកនាំអ្នកមីង ដឹកនាំនៅក្នុងព្រៃហ្នឹង?

ផល៖ នៅក្នុងព្រៃហ្នឹងមិនដឹងច្បាស់ពីណាដែរ ឪស៊ឹមអីហ្នឹង ។

ប៊ុនថន៖ ឪស៊ឹម?

ផល៖ ចាស ។

ប៊ុនថន៖ ឈ្មោះ អីស៊ឹម?

ផល៖ មិនដឹងជាស្អីស៊ឹមទេ ពួកគេហៅឪស៊ឹមៗ ។

ប៊ុនថន៖ គាត់ខាងកងវរៈ?

ផល៖ ទេ ខ្ញុំមិនដឹងទួលនាទីគាត់ដែរ ដឹងថាគាត់ហ្នឹង ដឹងថាឪស៊ឹមហ្នឹង ចំណាំតែពួកងទ័ពពួៗគាត់និយាយថា ឪស៊ឹម ហៅទៅប្រជុំណាណីចឹងទៅ ខ្ញុំមិនដឹងតួនាទីគាត់ផង ។

ប៊ុនថន៖ ចឹងឆ្នាំ៨០ហ្នឹង មីងរត់ឡើងមកជាមួយគាត់ដែរ?

ផល៖ ខ្ញុំឡើងមកជាមួយគាត់ តែគ្រាន់ឆ្លងទម្លេមេគង្គហើយខ្ញុំបែកពីគាត់ ។

ប៊ុនថន៖ ឆ្លងនៅម្តុំណាអ្នកមីង?

ផល៖ ឆ្លងម្តុំណាទេ ខ្ញុំដូចជាមិនចាំទេ កន្លែងហ្នឹង ម្តុំហ្នឹងគេហៅក្រឡាពោះយ៉ាងម៉េចទេ មិនថាអូរជំបូងមិនថាសៀមបូកខ្ញុំចំណាំមិនបានដែរ ។

ប៊ុនថន៖ ហ្នឹងនៅខេត្តស្ទឹងត្រែង?

ផល៖ នៅស្ទឹងត្រែង ។

ប៊ុនថន៖ ឆ្លងច្រើនគ្នាទេ?

ផល៖ ឆ្លងច្រើន អ្នកឆ្លងរួចរស់នៅទៅ អ្នកឆ្លងមិនរួចស្លាប់ទៅ ។

ប៊ុនថន៖ ចឹងមានស្លាប់ដែលឆ្លង?

ផល៖ ចាស ។

ប៊ុនថន៖ ស្លាប់ដោយសារយ៉ាងម៉េចវិញ?

ផល៖ ស្លាប់ដោយសារខ្សែរងាររហើយយើងនៅក្នុងទឹក ជិះក្បូនអណ្តែតទៅប្ញរងាររបេះដៃចេញពីក្បូនចឹងទៅណាស់ ។

ប៊ុនថន៖ ចឹងចេញមកម្តាយមីងមកជាមួយទេ?

ផល៖ ចាស!មកជាមួយ ។

ប៊ុនថន៖ ចឹងរយៈពេលប៉ុន្មានមីងឆ្លងទន្លេហ្នឹង?

ផល៖ មួយយប់មួយថ្ងៃ ។

ប៊ុនថន៖ ឆ្លងហើយមីងទៅណាទៀតមីង?

ផលៈ ឆ្លងទន្លេហ្នឹងហើយដើរតាមផ្លូវដែម ទៅតាមព្រៃផ្លូវដែមអីហ្នឹងមករហូតដល់ភ្នំដងរែក ។

ប៊ុនថនៈ ចឹងរយៈពេលប៉ុន្មានថ្ងៃបានឡើងដល់ភ្នំ?

ផលៈ ចាស!មិនមែនថ្ងៃទេ ច្រើនណាស់ ខ្ញុំមកពីខែ៦មកដល់លើភ្នំខាងលិចខែ៩ ។

ប៊ុនថនៈ ដល់ខែ៩បានឡើងដល់លើភ្នំ?

ផលៈ ចាស ។

ប៊ុនថនៈ នៅភ្នំហ្នឹងខាងខ្មែរយើងឬខាងថៃ?

ផលៈ ភ្នំដងរែកហ្នឹងមិនដឹងថាខ្មែរមិនដឹងថៃ ។

ប៊ុនថនៈ មកខាងដីខ្មែរឬខាងដីថៃកាលហ្នឹង?

ផលៈ ឡើងទៅលើភ្នំផុតហើយមិនដឹងថាដីខ្មែរជំរៅប៉ុន្មាន ដីថៃជំរៅប៉ុន្មានខ្ញុំដើរមិនដឹងថាដីថៃត្រឹមណាដីខ្មែរត្រឹមណាផង ។

ប៊ុនថនៈ តែកន្លែងហ្នឹងគេហៅអីវិញមីង?

ផលៈ គេហៅទន្លេល្អៅ ។

ប៊ុនថនៈ មុំបីហ្នឹង មីងទន្លេល្អៅ?

ផលៈ មុំបីខ្ញុំទើបឮឥឡូវនេះ ពីមុនខ្ញុំស្គាល់តែទន្លេល្អៅហ្នឹង ។

ប៊ុនថនៈ ស្គាល់តែទន្លេល្អៅ?

ផលៈ ចាស ។

ប៊ុនថនៈ ទៅដល់ហ្នឹងគេបែកចែកយ៉ាងម៉េចមីង គេបែងចែកមីងឲ្យរស់នៅយ៉ាងម៉េចទៅ?

ផលៈ កាលហ្នឹងគេបែងចែកធ្វើជាកងដឹកជញ្ជូន ជញ្ជូនគ្រាប់ ជញ្ជូនអង្ករអីហ្នឹង យកឲ្យកងទ័ពចឹងទៅកាលហ្នឹង ។

ប៊ុនថនៈ ជញ្ជូនទៅខាងណាវិញមីង?

ផលៈ ជញ្ជូនមកក្រោមមកស្រុកខ្មែរហ្នឹង គេហៅឲ្យជញ្ជូនចឹងទៅ កងទ័ពនៅត្រង់ណាជញ្ជូនទៅត្រង់ហ្នឹងទៅ ។

ប៊ុនថនៈ ជញ្ជូនទៅឲ្យគេនៅសមរភូមិមុខ?

ផលៈ ចាស ។

ប៊ុនថនៈ គេបែងចែកមីងនៅក្នុងកងប៉ុន្មានមីង?

ផលៈ ចាស!នៅ៨១ហ្នឹង ។

ប៊ុនថនៈ ៨០១?

ផលៈ អត់ទេ ៨១ ។

ប៊ុនថន: គេហៅ៨១?

ផល: ចាស ។

ប៊ុនថន: ៨១ហ្នឹងនៅក្នុងកងពលប៉ុន្មានដែរ?

ផល: នៅកងពល៨០១ ។

ប៊ុនថន: មីងនៅជាមួយពីណា៨១ហ្នឹង ប្រធានកង?

ផល: ប្រធានកងស្លាប់ហើយដឹង ។

ប៊ុនថន: ស្រីឬប្រុស?

ផល: ស្រី ឈ្មោះ ជឿន ។

ប៊ុនថន: ជឿន ហ្នឹងគាត់អ្នកស្រុកណាដែលមីង?

ផល: អត់ដឹងទេ ។

ប៊ុនថន: ៨១ហ្នឹងកងវរសេនាធំឬវរសេនាតូច?

ផល: វរសេនាធំ ។

ប៊ុនថន: មីងនៅដឹកជញ្ជូនទៅខាងអូរជ្រៅហ្នឹងនៅខាងខេត្តណាមីង?

ផល: មិនដឹងថាខេត្តណាផង មិនដឹងខេត្តណា ខេត្តព្រះវិហារឬអី ។

ប៊ុនថន: មិនដឹងជាខេត្តណាខ្ញុំមិនស្គាល់ដែរ ។

ផល: ខ្ញុំអត់ស្គាល់ដែរ មិនដឹងថាខេត្តណា ខ្ញុំនៅតែក្នុងព្រៃមិនដឹងមានខេត្តអីផង កាលហ្នឹងខ្ញុំនៅព្រៃ មិនដឹងថាមានខេត្តអីគេផង តែដឹងថា ប៉ែកខាងហ្នឹង ខេត្តព្រះវិហារ លើកមុនដាំក្បាន្ត បើខ្ញុំយល់ដឹងឥឡូវខេត្តព្រះវិហារ បើពីមុនខ្ញុំមិនដឹងថាខេត្តណាទេ ។

ប៊ុនថន: ចឹងមីងដឹកជញ្ជូនទៅម៉ុំតែខេត្តព្រះវិហារអត់មានឆ្លងទៅខេត្តណាទេ?

ផល: អត់ទេ ។

ប៊ុនថន: ចឹងគេដឹកជញ្ជូនតាមឡានឬតាមថ្មើរជើង?

ផល: តាមមនុស្សទូទៅ ទូអង្ករទូគ្រាប់ ។

ប៊ុនថន: អត់មានឡានទេ?

ផល: អត់ទេ ។

ប៊ុនថន: ចម្ងាយប៉ុន្មាន?

ផល: មិនដឹងថាចម្ងាយប៉ុន្មានទេ ដើរដេកផ្លូវមួយយប់បានដល់ ។

ប៊ុនថន: ទៅម្តងមានប៉ុន្មាននាក់?

ផល: ទៅម្តងច្រើនមានគ្នារាប់រយនាក់ ។

ប៊ុនថន: គេរៀបចំយ៉ាងម៉េចទៅបន្ទាក់គ្នាឬទៅដល់ទឹសដៅតែម្តង?

ផល: អត់មានបន្ទាក់គ្នាទេ ឧទាហរណ៍ថា ពួទៅត្រពាំងប្រាសាទចឹង ពួទៅឲ្យដល់តែម្តងទៅបើមិនដល់ដេកមួយយប់ ។

ប៊ុនថន: ដេកមួយយប់មកវិញ?

ផល: ចាស!មកវិញ យើងស្រួតដើរឲ្យដល់បើមិនដល់ដេកផ្លូវមួយយប់ទៀត ។

ប៊ុនថន: តែយើងមានស្បៀងអីត្រឹមទេ?

ផល: ចាស!យើងទៅចឹងយើងមានស្បៀងត្រៀមអស់ហើយ មានខ្លះទូគ្រាប់ មានខ្លះទូអង្ករអីចឹង ។

ប៊ុនថន: ចឹងនៅខាងកងដឹកជញ្ជូនមីងមានហូបគ្រប់គ្រាន់ទេ?

ផល: ចាស!មានគ្រប់គ្រាន់ ។

ប៊ុនថន: យើងមានរបបបើកឬមួយយ៉ាងម៉េច?

ផល: ចាស!របបបើក ។

ប៊ុនថន: ខាងគ្រប់គ្រងធំតែម្តងខាងកងពល៨០១ហ្នឹង?

ផល: ចាស!តាសារឿន ០៥ហ្នឹង ។

ប៊ុនថន: ចឹងនៅពេលមីងដឹកជញ្ជូនចឹងមានជួបហេតុការវាយគ្នាអីទេមីង?

ផល: ជួបចឹងទៅរត់ទៅ ។

ប៊ុនថន: ជួបជាមួយខាងណាវិញ?

ផល: ជួបជាមួយយួន ។

ប៊ុនថន: តែមីងអត់មានកាំភ្លើងនៅដៃទេ?

ផល: អត់មានទេ ដៃទទេ ពួៗនាំរត់ៗទៅ ។

ប៊ុនថន: ចឹងពេលទៅមានអ្នកនាំ?

ផល: ចាស!ពួៗនាំចឹងទៅដូចថានារី១០០នាក់ចឹងទៅ ពួៗប្អូនប្រាំនាក់ចឹងទៅគេនាំរត់ទៅណាយើងរត់ទៅហ្នឹងទៅ ។

ប៊ុនថន: អត់មានវាយតវិញទេ?

ផល: អត់ទេ ។

ប៊ុនថន: តែមានគ្រោះថ្នាក់អីទេមីង?

ផល: អត់ទេ ព្រោះមានប្រុសៗពីរបីនាក់ចឹងដើរស៊ើបមើលពីចម្ងាយ គេទៅឆ្ងាយមុនយើងពីរនាក់ចឹងទៅ ។

ប៊ុនថន: បានយើងទៅតាមក្រោយ?

ផលៈ ចាស!បានយើងទៅតាមក្រោយ ហើយគេឲ្យទៅមុនពីបីនាក់ចឹងទៅ នៅក្រោយផុតយើងនោះពីរបីនាក់ទៀតទៅ នៅកណ្ដាលពីរបីនាក់ចឹងមក ។

ប៊ុនថនៈ ចឹងមីងកាលហ្នឹងមានគ្រួសារហើយនៅ?

ផលៈ នៅ ។

ប៊ុនថនៈ មិនទាន់រៀបទេ?

ផលៈ ចាស ។

ប៊ុនថនៈ ចឹងមីងនៅទន្លេល្ពៅហ្នឹងបានប៉ុន្មានឆ្នាំ?

ផលៈ នៅតាំងពីឆ្នាំ៨០ដល់៨៥ ។

ប៊ុនថនៈ ចឹងមីងនៅបាន៥ឆ្នាំ?

ផលៈ ចាស ។

ប៊ុនថនៈ ចឹងមីងនៅតែខាងកងដឹកជញ្ជូនទេអត់មាននៅខាងណាទៀតទេ?

ផលៈ ចាស!អត់ទេ នៅពី៨០ដល់៨៥ហ្នឹងមានផ្ទះនៅ លែងនៅក្រោមដើមឈើដូចឆ្នាំ៧៩ហើយកាលហ្នឹង ។

ប៊ុនថនៈ ផ្ទះយ៉ាងម៉េចដែលមីង?

ផលៈ ផ្ទះធ្វើខ្ទមយើងធ្វើល្មមៗម៉ានៅបានប្រហែលរោងហ្នឹងចឹងទៅ ។

ប៊ុនថនៈ ស្នាក់នៅរួមគ្នាឬយ៉ាងម៉េច?

ផលៈ ទេ ស្នាក់នៅរោងខ្ទម ។

ប៊ុនថនៈ ចឹងដូចមីងអី?

ផលៈ ចាស!ខ្ញុំពីរនាក់ម៉ែចឹងទៅពីរនាក់ម៉ែទៅ ។

ប៊ុនថនៈ ចឹងដល់ពេលធ្វើការ?

ផលៈ ដល់ពេលធ្វើការគេប្រាប់ចឹងមក ថាយកគ្រាប់ទៅណាយកអង្ករទៅខាងណាចឹង គេប្រាប់យើងពីល្ងាចចឹងទៅ យើងទៅ ។

ប៊ុនថនៈ ចឹងមានអ្នកដើរប្រាប់?

ផលៈ ចាស!មានអ្នកដើរប្រាប់ ។

ប៊ុនថនៈ មួយកងមីងមានប៉ុន្មាននាក់ កង៨១?

ផលៈ ចាស!ខ្ញុំអត់ដឹងដែរ មានច្រើនដែរ ។

ប៊ុនថនៈ ចឹងជឿន ហ្នឹងប្រធានកងមីង?

ផលៈ ចាស ។

ប៊ុនថន: ចឹងរហូតមកក្រោយទៀត គាត់ទៅណា?

ផល: អត់ទេ ប្រធានកងហ្នឹងត្រឹម៨៥ហ្នឹងដល់ហើយគាត់ទៅណាខ្ញុំមិនបានដឹងគាត់ទៅណាដែរ ។

ប៊ុនថន: ចឹង៨៥ហ្នឹងមីងរត់ទៅណាវិញ?

ផល: រត់ពីទន្លេល្ពៅទៅស្រុកថៃទៅ ។

ប៊ុនថន: ទៅថៃហ្នឹងទៅណា?

ផល: រត់ទៅពីទន្លេល្ពៅទៅដល់ភូមិថៃ ថៃវាដឹកមកយកមកដាក់ត្រង់ណាទៀតទេ ខ្ញុំដូចជាមិនស្គាល់ដែរ ដូចជាចំបក់កោង ទុយយោទឹកមិនដឹងថា ខេត្តណាទេថៃ ខ្ញុំមិនដឹងដែរ ។

ប៊ុនថន: ចឹងកាលហ្នឹងយ៉ាងម៉េចបានជារត់ចឹងមីង?

ផល: យួនវាយ យួនបាញ់ ។

ប៊ុនថន: វាយខ្លាំងមីង?

ផល: ចាស!វាយខ្លាំងមានស្លាប់ច្រើនដែរ ។

ប៊ុនថន: ស្លាប់ខាងណា?

ផល: ស្លាប់ប្រជាជន ស្លាប់ប្រពន្ធកងទ័ពអីហ្នឹងស្លាប់ មានអ្នកស្លាប់ពោះធំចឹងទៅ មានអ្នកជាន់មីនដាច់ជើងចឹងទៅ មានអីច្រើនដែលហ្នឹង ។

ប៊ុនថន: មីនខាងណាជាអ្នកដាក់?

ផល: អត់ដឹងទេ ដឹងថាខាងណាអ្នកដាក់ផង ។

ប៊ុនថន: ចឹងខាងវៀតណាមមានស្លាប់មានរបួសអីទេ.?

ផល: អត់ដឹង ព្រោះវៀតណាមវាយក្រោមដីខ្មែរចឹងទៅ ហើយយើងនៅនោះមិនរត់មិនដឹងថាមានស្លាប់មានរស់អី យើងយ៉ាងម៉េចដឹង បើយើងចេះតែរត់ ។

ប៊ុនថន: ចឹងមកខាងថៃនេះនៅណានៅខាងចំបក់កោង?

ផល: ចាស!ចេះតែនៅចឹងទៅចំបក់កោង ទុយយោទឹក ហូរហែរមក លែងមានផ្ទះសំបែងអីហើយពីឆ្នាំ៨៥មកហ្នឹងនោះ ។

ប៊ុនថន: ចឹងនៅរបៀបយ៉ាងម៉េចវិញមីង?

ផល: នៅរបៀបក្នុងព្រៃចឹងទៅ នៅរបៀបដូចឆ្នាំ៧៩ចឹងទៅ ។

ប៊ុនថន: តែមីងនៅក្នុងកងដឹកជញ្ជូនដដែល?

ផល: ខ្ញុំដល់ពេល៨៥ហ្នឹងខ្ញុំលែងហើយ ខ្ញុំមានប្ដីហើយ នៅក្នុងប្រជាជន ។

ប៊ុនថន: ចឹងនៅក្នុងប្រជាជន?

ផល: ចាស ។

ប៊ុនថន: គ្រួសារអ្នកមីងគាត់ធ្វើអីដែរ?

ផល: កាលហ្នឹងគាត់ធ្វើទាហាន ។

ប៊ុនថន: គាត់ឈ្មោះអីដែលមីង?

ផល: គាត់ឈ្មោះ នឿន ។

ប៊ុនថន: ស្អីនឿន?

ផល: អឺ នឿន ។

ប៊ុនថន: គាត់នៅខាងកងពលប៉ុន្មានមីង?

ផល: ៨០១ ។

ប៊ុនថន: ៨០១ហ្នឹងដែរ?

ផល: ចាស!៨០១ ។

ប៊ុនថន: ចឹងមីងទៅខាងទុយយោទឹក ចំបក់កោង ប្ដីមីងទៅតាមដែរ គាត់ទៅជាមួយគ្នាឬយ៉ាងម៉េច?

ផល: អត់ផង គាត់ទៅសមរភូមិ តែមិនដឹងថាសមរភូមិត្រង់ណាយើងមិនបានដឹងផង ។

ប៊ុនថន: ចឹងទៅតែមីងទេ?

ផល: ចាស!ទៅតែពីរនាក់កូនបីនាក់ម៉ែ ដល់ម៉ែស្លាប់ទៅនៅតែពីរនាក់កូន ។

ប៊ុនថន: ចឹងម្ដាយមីងស្លាប់ឆ្នាំ៨៥?

ផល: ចាស!ស្លាប់ឆ្នាំ៨៥ខែ២ នៅចំបក់កោងហ្នឹងឯង ។

ប៊ុនថន: ចឹងកាលហ្នឹងមីងនៅជីវភាពអីពីណាជាអ្នកឧបត្ថម្ភ?

ផល: តាម៉ុក ។

ប៊ុនថន: ចឹងតាម៉ុក អ្នកឧបត្ថម្ភ?

ផល: ចាស ។

ប៊ុនថន: ចឹងកាលហ្នឹងមីងមានរត់ទៅជំរំទេ?

ផល: អត់ទេ នៅជាមួយតាម៉ុក ។

ប៊ុនថន: ចឹង៨៥ហ្នឹង មីងមកនៅជាមួយតាម៉ុក តែម្ដង?

ផល: ចាស ។

ប៊ុនថន: នៅខាងណាវិញ គេមាន១០០១-១០០២-១០០៣មីង?

ផល: នៅ១០០១ឆ្នាំ៨០ដល់៨៥នៅ១០០១ហើយដល់ពេលរត់មកនៅចំបក់កោងហ្នឹងមិនដឹងជា ១០០០ប៉ុន្មានទេ មិនដឹង១០០០ប៉ុន្មានទេត្រង់ហ្នឹង ។

ប៊ុនថន: ចឹង១០០១រត់មកនៅចំបក់កោង?

ផលៈ ចាស ។

ប៉ុនថនៈ គេហៅ១០០០ប៉ុន្មាន១០០២ឬ១០០៣?

ផលៈ អត់មាន១០០២-១០០៣ទេ អត់ដឹងគេហៅ១០០០ប៉ុន្មានផង គេហៅចំបក់កោងទុយយោទឹកហ្នឹង ជម្រៀសមួយក្អេតៗចឹងទៅត្រង់នេះពីរបីយប់ទៅត្រង់នោះពីរបីយប់ចឹងទៅចេះតែនៅៗទៅ ។

ប៉ុនថនៈ ចឹងទុយយោទឹកបច្ចុប្បន្ននៅជាប់ខាងណាវិញ?

ផលៈ ចាស ។

ប៉ុនថនៈ ខាងចំបក់កោងទុយយោទឹក បច្ចុប្បន្ននៅខាងខេត្តព្រះវិហារឬខាងឧត្តរមានជ័យ?

ផលៈ នៅខាងដីថៃ ។

ប៉ុនថនៈ ចឹងនៅខាងថៃវិញ?

ផលៈ ចាស!ដីថៃ ។

ប៉ុនថនៈ តែបើសិនជាប់ ជាប់ខាងណា?

ផលៈ បើសិនជាជាប់ ទល់ខាងនេះជាប់ខេត្តឧត្តរមានជ័យ ។

ប៉ុនថនៈ ចឹងមិនមែន?

ផលៈ មិនមែនព្រះវិហារទេ ។

ប៉ុនថនៈ ចឹងមិនមែនព្រះវិហារទេ?

ផលៈ ចាស ។

ប៉ុនថនៈ ចឹងតាម៉ុក អ្នកគ្រប់គ្រង?

ផលៈ ចាស ។

ប៉ុនថនៈ នៅជិតនេះទេ ជិតអូរស្មាច់ទេ?

ផលៈ ចាស!អូរស្មាច់ក៏ខ្ញុំធ្លាប់នៅ ។

ប៉ុនថនៈ ចឹងនេះនៅមុនអូរស្មាច់?

ផលៈ ចាស!រួចពីហ្នឹងទៅបានទៅនៅអូរស្មាច់ ។

ប៉ុនថនៈ ឆ្នាំណាមីងទៅអូរស្មាច់?

ផលៈ ចាស!ខ្ញុំទៅអូរស្មាច់ហ្នឹងខ្ញុំនៅឆ្នាំ៨៥ហ្នឹង ក្នុងឆ្នាំ៨៥ហ្នឹងវាវែងឆ្ងាយ ក្នុងឆ្នាំ៨៥យើងរត់ពីទន្លេល្ពៅមក មកទុយយោទឹកហើយចំបក់កោងហ្នឹងទៅ ដល់ខែ៧ខែ៨យើងមួយប្រាំងមួយវស្សាដល់ខែ១០ទៅនៅអូរស្មាច់ ។

ប៉ុនថនៈ បាទ ។

ផលៈ ឆ្នាំ៨៥-៨៦-៨៧នៅអូរត្រាវមានខ្ទមនៅ ។

ប៊ុនថនៈ ចឹងខែ១០ឆ្នាំ១៩៨៥ដដែល មីងទៅនៅអូរត្រាវ?

ផលៈ ចាស!ទៅនៅអូរត្រាវហ្នឹងឆ្នាំ៨៦-៨៧យើងធ្វើខ្ទមធ្វើជំរកអីហ្នឹង ព្រោះដីថៃ ។

ប៊ុនថនៈ បាទ ។

ផលៈ យើងធ្វើបានរយៈពេលបីឆ្នាំ បានចេញទៅទៀត មើលបីឆ្នាំចឹងហើយឆ្នាំ៨៥ដល់៨៧ ។

ប៊ុនថនៈ ចឹងពេលនៅអូរត្រាវហ្នឹងមីងនៅជាប្រជាជនទេ?

ផលៈ ចាស!ប្រជាជនក្នុងកង៨១ហ្នឹងឯង ។

ប៊ុនថនៈ ចឹងនៅក្នុងកង៨១ដដែល?

ផលៈ ចាស ។

ប៊ុនថនៈ នៅក្នុងកងហ្នឹងមីងនៅក្នុងជំរំឬយ៉ាងម៉េច?

ផលៈ នៅធម្មតា ប្រជាជនយើងធម្មតា អត់មានជំរំអីទេ ។

ប៊ុនថនៈ ចឹងអត់មានជំរំទេ?

ផលៈ អត់មានជំរំអីទេ តែយើងនៅតាមកងធម្មតា តែមានខាងកាកបាទគេមកចែកឲ្យដែរ ថ្ងៃសៅរ៍មួយអាទិត្យចឹងគេយកល្ពៅមកឲ្យចឹងមក ។

ប៊ុនថនៈ បាទ ។

ផលៈ តែអត់មានជំរំនៅទេ នៅជំរំខ្មែរក្រហម ។

ប៊ុនថនៈ ចឹងមីងនៅដាច់ដោយឡែកពីប្រជាជនមីង?

ផលៈ នៅជាមួយប្រជាជនហ្នឹង ។

ប៊ុនថនៈ នៅជាមួយប្រជាជន?

ផលៈ ចាស ។

ប៊ុនថនៈ ចឹងប្រជាជននៅលាយឡំគ្នា?

ផលៈ ចាស!នៅលាយឡំហ្នឹង ខ្ញុំភូមិ៨១គេភូមិ៨៥ចឹងទៅ ៨៤-៨៥ចឹងទៅណាស់ ភូមិតគ្នាចឹងទៅ ។

ប៊ុនថនៈ ចឹងពីណានៅក្តោបរួមនៅហ្នឹង គ្រប់គ្រងរួម?

ផលៈ នៅក្នុងភូមិហ្នឹង កាលមុនមានឈ្មោះ យាយរុន ។

ប៊ុនថនៈ យាយរុន?

ផលៈ ចាស!តែឥឡូវមិនដឹងជាគាត់ទៅណាទេ តាំងពី៨៥-៨៦-៨៧ហ្នឹងមកមិនដឹងជាគាត់ទៅណាខ្ញុំមិនបានដឹងដែរ ។

ប៊ុនថនៈ ចឹងយាយរុន គាត់គ្រប់គ្រងក្នុងភូមិហ្នឹង?

ផលៈ ចាស!គ្រប់គ្រងភូមិ៨១ ។

ប៊ុនថនៈ ចឹងគេហៅភូមិ៨១ចឹងតែម្តង?

ផលៈ ចាស ។

ប៊ុនថនៈ ចឹងជីវភាពនៅហ្នឹងមានខ្វះខាតមានអីទេ?

ផលៈ អត់មានខ្វះទេ ។

ប៊ុនថនៈ ចឹងដូចជាអង្ករអីខាងកាកបាទក្រហមគេបើកឲ្យ?

ផលៈ ចាស!ខាងតាម៉ុក បើកឲ្យ ។

ប៊ុនថនៈ ចឹងតាម៉ុក បើកឲ្យ?

ផលៈ ចាស ។

ប៊ុនថនៈ ចឹងមីងថា ខាងកាកបាទ?

ផលៈ កាកបាទ គេឲ្យតែបន្លែ ។

ប៊ុនថនៈ ចឹងឲ្យតែបន្លែទេ?

ផលៈ ចាស ។

ប៊ុនថនៈ ចឹងតាម៉ុក គាត់ឲ្យអីវិញ?

ផលៈ តាម៉ុក គាត់ឲ្យអង្ករ ទឹកត្រី ប្រហុក ចឹងទៅ តាមអាទិត្យតាមខែចឹងទៅ ជួបមួយខែគាត់ឲ្យប៉ុណ្ណា គាត់ឲ្យអង្ករគាត់ឲ្យប្រហុកអីប៉ុណ្ណាចឹងតាមមិនសូវសម្បូរ ។

ប៊ុនថនៈ បាទ!មីងនៅ៨១ហ្នឹងរហូតដល់ឆ្នាំណា?

ផលៈ ចាស!តាំងពីហ្នឹងមកវែងឆ្ងាយមកដល់យើងផ្តាច់ខ្លួននេះ ឆ្នាំ៩៨ ។

ប៊ុនថនៈ ផ្តាច់ខ្លួន៩៨?

ផលៈ ចាស ។

ប៊ុនថនៈ មីងនៅដល់ឆ្នាំ៩៨បានចុះមក?

ផលៈ ចាស!ខ្ញុំចុះមកពីលើភ្នំហ្នឹងវាវែងឆ្ងាយណាស់ ខ្ញុំចុះមកពីឆ្នាំ៨៧-៨៨ ដល់៩២ខ្ញុំចុះមកពីដីថៃ ឆ្នាំ៩២ហ្នឹងចុះមកពីដីថៃវិញហើយ មកនៅតាមដីទំនប់ដាច់ហ្នឹង ។

ប៊ុនថនៈ មីងមកនៅនេះតែម្តង?

ផលៈ ចាស ។

ប៊ុនថនៈ នៅភូមិហ្នឹងតែម្តង?

ផលៈ ចាស!ភូមិហ្នឹងផ្ទះនៅក្បែរវត្តនោះដឹបូង ។

ប៊ុនថន: នៅភូមិទួលចារ?

ផល: អត់ទួលចារទេ ភូមិ៨១ ។

ប៊ុនថន: ចឹងបច្ចុប្បន្ន ទួលចារហ្នឹង?

ផល: ចាស!ទួលចារនេះដាក់នៅក្នុងឆ្នាំ២០០០ អត់ទេ ឆ្នាំ៩៨-៩៩ហ្នឹងហើយភូមិទួលចារ ។

ប៊ុនថន: ចឹង៩៨-៩៩?

ផល: ចាស ។

ប៊ុនថន: ចឹងមីងចុះមកនៅឆ្នាំ៩២មុនបោះឆ្នោត កាលបោះឆ្នោតឆ្នាំ៩៣?

ផល: ហ្នឹងហើយ ។

ប៊ុនថន: ចឹងគ្រួសារមីងមានមកជាមួយទេ?

ផល: អត់ទេ គ្រួសារខ្ញុំគាត់ធ្វើទាហានមិនដឹងថាគាត់ទៅនៅខាងណាខាងណីផង មកពីរនាក់កូន ។

ប៊ុនថន: ចឹងឆ្នាំ៩២ហ្នឹង មីងមកនៅរហូតតែម្ដងឬមីងមានរត់ទៅណាទៀត?

ផល: អត់មានបាននៅរហូតទេ នៅបានមួយឆ្នាំចឹងទៅរត់ នៅខែវស្សានៅជាប់បានយូរបើនៅខែប្រាំងមិននៅបានយូរទេ រត់ទៅខាងអន្លង់វែង ។

ប៊ុនថន: ចឹងរត់ទៅខាងអន្លង់វែងវិញ?

ផល: ចាស!ហូរហែរប៉ុន្មានឆ្នាំតាំងពី៩២មកដល់ក្នាឆ្នាំ៩៨ ទើបមកនៅឆ្នាំ៩៨ហ្នឹង ។

ប៊ុនថន: ចឹងរត់ចុះឡើងៗ?

ផល: ចាស!រត់ចុះឡើង ព្រៃទំនប់ដាច់ហ្នឹងទៅអន្លង់វែងទៅមកត្រឹមហ្នឹងឯង ប៉ុន្មានឆ្នាំហ្នឹង ។

ប៊ុនថន: បាទ ។

ផល: អត់មានផ្ទះកំណត់បានទេ ប៉ុន្មានឆ្នាំហ្នឹង ទើបកើតបានឆ្នាំ៩៨ហ្នឹង បានកំណត់ ។

ប៊ុនថន: ចឹងកាលមីងមកនៅជាកង៨១ដដែល?

ផល: ចាស!៨១ដដែល ។

ប៊ុនថន: ចឹងនៅដឹកជញ្ជូនចឹងទៅ?

ផល: អត់ទេ អត់មានទេ អត់មានអីទៀតទេ តាំងពីឆ្នាំ៨៥មក អត់មានដឹកជញ្ជូនទៀតទេ ព្រោះខ្ញុំចូលក្រុមវ័យចាស់ ។

ប៊ុនថន: វ័យចាស់ហ្នឹងធ្វើអីវិញមីង?

ផល: អត់មានធ្វើអីទេ មានបិតចំរូង បន្តិចបន្តួចចឹងទៅ ។

ប៊ុនថន: មានបិតចំរូងនិងមានធ្វើអីទៀតមីង?

ផលៈ បើយើងនិយាយឲ្យចំការងារបម្រើរដ្ឋអត់មានអីក្រៅពីបិតតែចំរូងមួយមុខហ្នឹងទេ អាហ្នឹងរឿងការងាររួម ក្រៅពីហ្នឹងធ្វើស្រែធ្វើចម្ការខ្លួនឯងចឹងទៅណាស់ ។

ប៊ុនថនៈ បិតចំរូងហ្នឹងគេយកទៅដាក់ខាងណាខ្លះ?

ផលៈ អត់ដឹងផង ។

ប៊ុនថនៈ ចឹងអត់ដឹងទេ ចឹងគ្រាន់យើងបិតបាន?

ផលៈ ចាស! គ្រាន់យើងបិតបានចឹង កងទ័ពគេមកប្រមូលយកដឹកឡានយកទៅបាត់ទៅមិនដឹងជាគេយកទៅណាខ្ញុំមិនបានដឹងផង ។

ប៊ុនថនៈ បិតរបៀបយ៉ាងម៉េច មីងអាចរៀបរាប់បានទេ ចំរូងមានប្រវែងប៉ុន្មាន?

ផលៈ ចំរូងប្រវែង ។

ប៊ុនថនៈ គេធ្វើអំពីអី?

ផលៈ គេធ្វើអំពីឫស្សី ។

ប៊ុនថនៈ ប្រវែងប៉ុន្មាន?

ផលៈ ប្រវែងប្រហែលជាបីតឹក ។

ប៊ុនថនៈ បីតឹក?

ផលៈ ចាស ។

ប៊ុនថនៈ ខ្ពស់ៗមីង?

ផលៈ ចាស ។

ប៊ុនថនៈ ចឹងដល់ពេលដោត គេដោតយ៉ាងម៉េចទៅមីង មានស្រួចទេ?

ផលៈ ស្រួចទាំងសងខាង គ្រាន់ដឹងថាដឹក តែមិនដឹងថាគេយកទៅដាក់ខាងណាអីទេ ។

ប៊ុនថនៈ តែរបៀបដាក់យ៉ាងម៉េចទៅមីង?

ផលៈ អត់ដឹងទេ ។

ប៊ុនថនៈ មានកំណត់ឲ្យបិតទេ?

ផលៈ គេមានកំណត់ថា ដូចក្នុងមួយខែចឹងយក៥០០ឬ៣០០ចឹង យើងបិតឲ្យគេហើយគ្រប់ទៅ យើងធ្វើស្រែចម្ការបានតាមស្រួលចឹងទៅ ។

ប៊ុនថនៈ ចឹងប៉ុន្មានថ្ងៃគេមកប្រមូលម្តង?

ផលៈ ចំរូងហ្នឹងកងទ័ពគេ១០ថ្ងៃគេមកយកម្តង យើងបិតហើយមុខផ្ទះចឹងយើងគៗទៅមួយក្រុមៗ ប៉ុន្មានគ្រួសារចឹងយើងគមួយដុំទៅ ហើយទុកទៅគេមកយកថ្ងៃណាយកថ្ងៃហ្នឹងទៅ ។

ប៊ុនថនៈ ចឹងផ្គត់ផ្គង់ខាងជីវភាពអីយ៉ាងម៉េចដែរ?

ផលៈ ចាស!ជីវភាពយើងធ្វើស្រែខ្លួនយើងហូបចឹងទៅ ។

ប៊ុនថនៈ ត្រីសាច់ហូបអី?

ផលៈ ត្រីសាច់ហូបអីអត់ រកបានខ្លួនយើងក្តាមខ្យងក៏ហូបទៅបើអត់ស្ងួតទទេៗទៅ ។

ប៊ុនថនៈ ចឹងគេមានខបគ្គម្ភទេ?

ផលៈ អត់មានពីណាខបគ្គម្ភទៀតទេ អត់មានទេ ។

ប៊ុនថនៈ ចឹងអត់មានខបគ្គម្ភខ្លះជាត្រីខអីមានទេ?

ផលៈ អត់មានទេ ។

ប៊ុនថនៈ ចឹងសម្លៀកបំពាក់?

ផលៈ សម្លៀកបំពាក់ក៏អត់ដែរ ។

ប៊ុនថនៈ ពីឆ្នាំណាទៅ?

ផលៈ ពីឆ្នាំ៩៣ទៅ ។

ប៊ុនថនៈ ចឹងលែងមានខបគ្គម្ភហើយ?

ផលៈ ចាស ។

ប៊ុនថនៈ ចឹងបានមកពីណាវិញទៅ?

ផលៈ បានមកពីណាពីមុនមកយើងចេះតែសន្សំសំចៃទៅ មានជ្រូកអីកាប់ដូរគ្នាចឹងទៅ គេអ្នកមានបានមកចឹងដូរសាច់ជ្រូក មានមាន់អីចឹងទៅ ។

ប៊ុនថនៈ ចឹងយើងអាចរកស៊ីបានទេ?

ផលៈ អត់ អត់ដឹងថាទៅរកស៊ីអីណា ។

ប៊ុនថនៈ ចឹងអត់មានដោះដូរជាមួយខាងថៃអីអត់មានទេ?

ផលៈ អត់ អត់មានលុយទៅផង តាំងពីឆ្នាំ៩៨មក មិនដែលបានជួបថៃអីផង ។

ប៊ុនថនៈ ចឹងឆ្នាំ៩៨ហ្នឹង មីងមកនៅភូមិនេះតែម្តង?

ផលៈ ចាស ។

ប៊ុនថនៈ ភូមិ៨១?

ផលៈ ចាស!តាំងពី៩៣ដល់ឥឡូវហ្នឹងនៅហ្នឹងរហូត តែមិនបាននៅរហូតទេ ពី៩២ទៅមកៗដល់៩៨ផ្តាច់ខ្លួនហ្នឹងយើងនៅត្រង់ហ្នឹងតែម្តង អត់មានទៅណាមកណាទៀតទេ ។

ប៊ុនថនៈ ចឹងបន្ទាប់ពីឆ្នាំ៩៨ហើយហ្នឹង មីងមានធ្វើអីទៀតមុខរបរ?

ផលៈ ធ្វើស្រែ ។

ប៊ុនថនៈ អត់មានចូលខាងកងទ័ពទេ?

ផលៈ អត់ទេ ។

ប៊ុនថនៈ ចុះគ្រួសារមីង?

ផលៈ គ្រួសារខ្ញុំកាលនេះហ្នឹង គាត់នៅធ្វើទាហាន តែដល់ឆ្នាំប៉ុន្មានទេ ឈប់ទៅខ្ញុំមិនបានចាំឆ្នាំដែរ ។

ប៊ុនថនៈ ពេលក្រោយសមាហរណ៍កម្មហើយ?

ផលៈ ចាស ។

ប៊ុនថនៈ ពេលគេកាត់រំសាយហ្នឹង?

ផលៈ ចាស ។

ប៊ុនថនៈ ឥឡូវគាត់ចូលនិវត្តន៍ហើយ?

ផលៈ ចាស ។

ប៊ុនថនៈ ចឹងពេលមានព្រឹត្តិការណ៍សម្លាប់សុន សេន អីមីងមាននៅហ្នឹងទេ?

ផលៈ ខ្ញុំនៅអូរស្វាយ ។

ប៊ុនថនៈ មីងមានដឹងទេ ពេលហ្នឹង?

ផលៈ អត់ដឹងផង ឃើញតែរូបថត ។

ប៊ុនថនៈ ចឹងបានឃើញរូបថតដែរ?

ផលៈ ចាស ។

ប៊ុនថនៈ កាលហ្នឹងគេដើរផ្សព្វផ្សាយឬមួយយ៉ាងម៉េចដែរ?

ផលៈ អត់ទេ រូបថតហ្នឹង គាត់បានមកចឹងមកឲ្យទៅខ្ញុំមើលខ្ញុំប្រាប់តៗគ្នាចឹងទៅ ខ្លះបានតែឮមិនបានឃើញចឹងទៅ ។

ប៊ុនថនៈ មីងឃើញមីងគិតយ៉ាងម៉េចដែរ កាលហ្នឹងមីងនៅក្រោមតាម៉ុក?

ផលៈ ចាស ។

ប៊ុនថនៈ ចឹងឃើញ មីងគិតថាអ្នកណាជាអ្នកធ្វើចឹង?

ផលៈ ចាស!ខ្ញុំគិតមិនដល់ដែរ ។

ប៊ុនថនៈ ចឹងក្រោយមកទៀតមានព្រឹត្តិការណ៍ចាប់ប៉ុល ពត អីចឹងមានបានដឹងទេ ដូចជាចាប់តាសារឿន ០៥អីចឹង?

ផលៈ ដឹងថាមានព្រឹត្តិការណ៍ហ្នឹង តែត្រង់គេចាប់ពេលណាខ្ញុំមិនបានដឹងផង ។

ប៊ុនថនៈ តែបានដឹង?

ផលៈ ចាស!ដឹងថាព្រឹត្តិការណ៍ហ្នឹងមានការច្របូកច្របល់ គេយ៉ាងម៉េចទេ ពេលហ្នឹងគេច្របូកច្របល់បាតុកម្មអីភ្នំពេញ មានបាតុកម្មលោក ខៀវ សំផន ហើយបានមកស្លាប់ សុន សេន ដល់ពេលស្លាប់ចឹងហើយក៏យើងខ្មែរក្រហមនៅក្នុងព្រៃហ្នឹងចេះតែរង្គោះរង្គើរហើយ ។

ប៉ុនថនៈ បាទ ។

ផលៈ ចេះតែរង្គោះរង្គើរចឹងទៅមានខ្មែរនៅក្នុងព្រៃចឹង មានលិចកើតចឹងទៅណាស់ មានពួកលិចពួកកើតចឹងវាពិបាកដែលកាលហ្នឹងពិបាកខ្លាំងដែរ ។

ប៉ុនថនៈ ចឹងមីងមិនបានដឹងច្បាស់ទេ?

ផលៈ ចាស!ដឹងតាមរូបថត ដឹងថាគេសម្លាប់ សុន សេន ចឹងតែមិនបានដឹងថាពីណាជាអ្នកសម្លាប់ ខ្ញុំមិនបានដឹងដែរ គេថតមកមានស្រីស្លាប់ចឹងទៅណាស់ គេស្រោតទាំងអស់ចឹងទៅណាស់ បានឃើញតែចឹងទេ អត់ដឹងថា ស្លាប់អីណាអ្នកណាអ្នកសម្លាប់អត់ដឹងដែរ ។

ប៉ុនថនៈ ចឹងមីងធ្លាប់ស្គាល់លោក ខៀវ សំផន អីដែរ?

ផលៈ អត់ដែលបានស្គាល់រូបពិតទេ ស្គាល់តាមរូបថត ។

ប៉ុនថនៈ ចឹងប៉ុល ពត?

ផលៈ ប៉ុល ពត ក៏ចឹងដែលមិនដែលបានឃើញរូបពិតទេ ។

ប៉ុនថនៈ ចឹងតាម៉ុក ធ្លាប់ជួបគាត់ទេ?

ផលៈ តាម៉ុក ធ្លាប់ជួប ។

ប៉ុនថនៈ ធ្លាប់នៅជាមួយគាត់ទេ?

ផលៈ អត់ទេ គ្រាន់ធ្លាប់ជួប ធ្លាប់ស្គាល់ដូចថា ស្គាល់ដឹងថាគាត់ហ្នឹងតាម៉ុក ចឹងទៅដឹងថាការរស់នៅក្រោមការដឹកនាំរបស់តាម៉ុក ។

ប៉ុនថនៈ ចឹងមីងនៅរហូតដល់ផ្ដាច់ខ្លួនមីងនៅភូមិហ្នឹងមានដីស្រែចម្ការអីធ្វើទេមីង?

ផលៈ ឥឡូវហ្នឹងមាន ។

ប៉ុនថនៈ មានប៉ុន្មានហាត់អីដែរ?

ផលៈ ដីមានច្រើនហាត់ដែលតែធ្វើវាអត់បានយើង ជួនកាលដល់ខែធ្វើស្រែចឹងខុះលុយ ខុះប្រេងអីចឹងទៅណាស់ ។

ប៉ុនថនៈ ធ្វើស្រែប្រាំង?

ផលៈ ទេ ធ្វើស្រែវស្សា ។

ប៉ុនថនៈ ចឹងដូចជាវត្តអីមានទេ កាលមីងមកដល់ឆ្នាំ៩២មីងមក?

ផលៈ អត់មានទេ ។

ប៊ុនថន: ពេលណាបានមាន?

ផល: មានវត្តហ្នឹងក្រោយពីផ្តាច់ខ្លួនហើយ ប្រហែលជាឆ្នាំ២០០០ ខ្ញុំមិនបានកត់ផង ។

ប៊ុនថន: វត្តណាវិញ?

ផល: វត្តយើងទំនប់ដាច់ហ្នឹង ។

ប៊ុនថន: ពីណាអ្នកបង្កើត?

ផល: ខ្ញុំមិនបានដឹងច្បាស់ទេ ពីណាអ្នកបង្កើតចឹងមានតែ យើងមកដល់ហ្នឹងយើងនៅក្រោមការដឹកនាំរបស់ ហ៊ុន សែន មួងហើយ តែអ្នកណាបង្កើតវត្តហ្នឹងខ្ញុំមិនបានចាប់អារម្មណ៍ដែរ ។

ប៊ុនថន: បាទ!តែមីងបានទៅទេ?

ផល: ចាស!ខ្ញុំបានទៅឃើញគេលើក ឃើញគេអីចឹងទៅណា ។

ប៊ុនថន: ចឹងមីងមានបានទៅធ្វើបុណ្យអីទេ?

ផល: ចាស!បានទៅតើ ។

ប៊ុនថន: ចឹងកាលពីមុនមកមីងមិនដែលបានទៅទេ តាំងពីសង្គ្រាម?

ផល: កាលពីសង្គ្រាមមិនថា មិនដែលបានទៅធ្វើបុណ្យទេ មិនដែលស្គាល់វត្តផងហ្នឹងតាំងពី៧៩ទល់គ្នាហ្នឹងនេះហ្នឹង ។

ប៊ុនថន: ចឹងទើបបង្កើតមីងមកនៅនេះហើយ បានទៅវត្តអី?

ផល: ចាស!កុំថាវត្ត ផ្សារក៏មិនដែលបានស្គាល់តាំងពី៧៩មកទល់និង៩៨ហ្នឹង ។

ប៊ុនថន: ចឹងមីងមិនចង់ទៅឬអត់មានពេលទៅ?

ផល: ចង់ទៅណាបើយើងអត់មានវត្តផង ។

ប៊ុនថន: ចឹងផ្សរអី?

ផល: ទៅផ្សារណាបើយើងនៅតែក្នុងព្រៃដើរចឹង ទៅរកផ្សារអីណាទៅ យើងចង់ទៅរកផ្សារអីណាបើយើងនៅតែក្នុងព្រៃ មានពីណាលក់អីអត់មានទេ ធ្វើជ្រូកមួយចឹងទៅចែកគ្នាហូបទៅ ។

ប៊ុនថន: បាទ ។

ផល: ពេលគេថាថ្ងៃហ្នឹងយួនវាយហើយ គេថាឲ្យត្រៀមសភាពការណ៍មិនស្រួលយ៉ាងវាយឬស្អីវាយចឹងកាប់ជ្រូកមួយចែកគ្នាជុំវិញហ្នឹង លីងដាក់ថាសដាក់ស្បោងអីសម្រាប់រត់ចេញទៅ ។

ប៊ុនថន: ចឹងមុនវាយយើងដឹងសភាពការណ៍មុន?

ផល: ចាស!ដឹងសភាពការណ៍មុន ។

ប៊ុនថន: ចឹងខាងកងទ័ពគេមកប្រាប់?

ផលៈ ចាស! គេមកប្រាប់ កង់ទ័ពគេមកប្រាប់ចឹងទៅ បើថ្ងៃហ្នឹងមានយន្តហោះគេថាមានយន្តហោះហើយ ។

ប៊ុនថនៈ មីងធ្លាប់ឆ្ងល់កាត់ចឹងមីងមានដែលនិយាយប្រាប់កូនចៅទេ?

ផលៈ អត់មានដែលនិយាយប្រាប់ផង ។

ប៊ុនថនៈ ចឹងអត់មានដែលនិយាយទាល់តែសោះ?

ផលៈ ចាស ។

ប៊ុនថនៈ ចឹងអ្នកជិតខាងអីមីង?

ផលៈ អ្នកជិតខាងចេះតែប្រាប់គ្នាហើយ អ្នកជិតខាងភាគច្រើននៅព្រៃទាំងអស់គ្នាមិនដឹងប្រាប់ថាយ៉ាងម៉េច ។

ប៊ុនថនៈ ចឹងដូចថាមានអ្នកមកពីឆ្ងាយចឹង មានការរាប់អានគ្នាយ៉ាងម៉េចដែលទៅ?

ផលៈ ចុះមានអី បើអ្នកមកពីឆ្ងាយរាប់អានគ្នាហើយតាមធម្មតាចឹងទៅ វាអត់មានរឿងអីព្រោកប្រាជ្ញអីផង ។

ប៊ុនថនៈ និយាយការរាប់អាន អ្នកជិតខាង ដូចថាយើងមកបែកពីភូមិស្រុកអី ការរាប់អានជិតស្និទ្ធធម្មតាយ៉ាងម៉េច?

ផលៈ ទេ ចិត្តរាប់អាន ជិតស្និទ្ធមិនថាជិតស្និទ្ធពេក មិនមានអ្នកជិតស្និទ្ធហើយមិនមានអ្នកអាក្រក់យើងមិនមានអ្នកអាក្រក់ អ្នកជម្លោះទាស់ទែងគ្នាចឹងក៏អត់មានដែរ ។

ប៊ុនថនៈ ចឹងមីងពីមុនជាតស៊ូនៅក្នុងព្រៃដល់បច្ចុប្បន្នមីងប្រៀបធៀបគ្នាខុសគ្នាយ៉ាងម៉េចទៅមីង?

ផលៈ និយាយថា មិនខុសគ្នាយ៉ាងម៉េច តាំងពីយើងដេកដីនៅដី យើងគ្មានទ្រព្យរបស់អីប្រើប្រាស់ស្រួលទេ ពេលមកឥឡូវយើងមានផ្ទះសំបែង មានផ្លូវដើរស្រួលបួលចឹង មានអារម្មណ៍ថាគ្រាន់បើជាងពីមុនដែរ តាំងពីគ្មានផ្លូវរត់ទៅកាត់ព្រៃកុំថាព្រៃចង្អៀតប៉ុណ្ណា ក៏យើងដើរបានដែរ តាំងពីមានផ្លូវមានផ្ទះ មានទូរទស្សន៍អីមើលចឹងទៅវាគ្រាន់រៀងធូរបន្តិចដែរ តែគ្មានអ្នកជួយ តែយើងមានលទ្ធភាពរកបានខ្លួនយើង ។

ប៊ុនថនៈ យើងមានសេរីភាព?

ផលៈ ចាស ។

ប៊ុនថនៈ ចឹងខ្ញុំដូចជាអស់សួរមីងហើយ តើមីងមានអីបន្ថែមទេ?

ផលៈ ខ្ញុំអត់មានអីទេ ។

ប៊ុនថនៈ ចឹងបច្ចុប្បន្នមីងមានកូនប៉ុន្មាននាក់?

ផលៈ ខ្ញុំមានកូន៥ នាក់ ។

ប៊ុនថនៈ មានបានរៀនសូត្រដែរ?

ផលៈ បានរៀនតែមិនបានចប់ចុងចប់ដើម មីបងរៀនបានត្រឹមថ្នាក់ទី៦ បន្ទាប់ទីមករៀនបានត្រឹមថ្នាក់ទី៨ ។

ប៊ុនថនៈ ទី៣?

ផលៈ ទី៣ បានត្រឹមថ្នាក់ទី៩ ។

ប៊ុនថនៈ ទី៤?

ផលៈ ទី៤ មិនទាន់ដឹងដែរ ដឹងថាវារៀនបានត្រឹមណា ទី៤ហ្នឹងរៀនបានត្រឹមថ្នាក់ទី៧ ហើយរាល់ថ្ងៃនេះ រគាន់ថាទៅមុខទៀតមិនដឹងថាវារៀនបានត្រឹមណា ។

ប៊ុនថនៈ ចឹងមានរៀបការអីខ្លះហើយ?

ផលៈ មានគ្រួសារពីរ នៅបីទៀត ។

ប៊ុនថនៈ ចឹងបីនាក់នៅក្នុងបន្ទុកមីង?

ផលៈ ចាស ។

ប៊ុនថនៈ ចឹងគ្រួសារមីងចូលនិវត្តន៍?

ផលៈ ចាស ។

ប៊ុនថនៈ មីងប្រកបរបរអីដែរ?

ផលៈ ប្រកបរបរអីមានស្រែមួយមុខគត់ ។

ប៊ុនថនៈ ចឹងខ្ញុំអរគុណច្រើន ។

ផលៈ ចាស ។

**ចប់**